**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០១៨/២១..........**ក.ប**/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ
# ស្តីពី
# វិធានការបង្ការជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ

ដើម្បីចូលរួមចំណែកបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងអំឡុងពេលព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់នាយក នាយិកា បុគ្គលិក មន្ត្រីរាជការ គ្រូ សាស្ត្រាចារ្យ សិស្ស-និស្សិត សិក្ខាកាម នៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទក្រសួង ដូចខាងក្រោម៖

១. ត្រូវរឹតបន្តឹងការអនុវត្តវិធានការសុខាភិបាល ជាពិសេសវិធានការ "៣ការពារ = ការពាក់ម៉ាស, ការលាងដៃ, និងការរក្សាគម្លាតសុវត្ថិភាពសង្គម" និងវិធានការ "៣កុំ = កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូលហើយប្រើម៉ាស៊ីនត្រជាក់, កុំទៅកន្លែងមានមនុស្សច្រើនកុះករដែលមិនដឹងប្រភពច្បាស់លាស់, និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា"។

២. ត្រូវតាមដានវត្តមាន និងសាកសួរស្ថានភាពសុខភាពសិស្ស-និស្សិត សិក្ខាកាម និងបុគ្គលិកទាំងឡាយណាដែលអវត្តមាន ឬទើបវិលត្រឡប់ពីបរទេស។

៣. ត្រូវបូកសរុប និងរាយការណ៍ជាបន្ទាន់ជូនក្រសួងសុខាភិបាល ក្នុងករណីរកឃើញមានការសង្ស័យពាក់ព័ន្ធដោយផ្ទាល់ក្តី ឬប្រយោលក្តីក្នុងព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ។

៤. ត្រូវអប់រំ ណែនាំ និងលើកទឹកចិត្តឱ្យគ្រប់បុគ្គលទាំងអស់កុំគេចវេះពីការធ្វើចត្តាឡីស័ក ដែលនាំឱ្យមានហានិភ័យដល់ខ្លួនឯងផង សុខភាពសាធារណៈផង និងត្រូវរងការពិន័យអន្តរកាលផង។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា នាយក នាយិកា បុគ្គលិក មន្ត្រីរាជការ គ្រូ សាស្ត្រាចារ្យ សិស្ស-និស្សិត សិក្ខាកាម នឹងចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

*ថ្ងៃសៅរ៍ ៩កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត

  *"ដើម្បីជូនជ្រាប និងសហការ"*
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ